ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ...១៧៦០១.......អពដ

L202107070454 | TD3110

ថ្ងៃសុក្រ ៦រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រើប្រាស់កម្មវិធីបង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ តាមទូរស័ព្ទដៃ និងការដឹកជញ្ជូនលតាបត្រ ដល់ទីកន្លែងរបស់ម្ចាស់យានជំនិះ

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានកិត្តិយស សូមជម្រាបជូនសាធារណជន ឬម្ចាស់យានជំនិះជាអ្នកជាប់ពន្ធដែលមានមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលជាកម្មវត្ថុនៃពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទមេត្តាជ្រាបថា ក្នុងបរិបទនៃការធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងវិស័យពន្ធដារ ស្របតាមគោលនយោបាយកែទម្រង់របស់រាជរដ្ឋាភិបាល អគ្គនាយកដ្ឋានពន្ធដារបានអភិវឌ្ឍមុខងារ សម្រាប់បង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទតាមទូរស័ព្ទដៃក្នុងកម្មវិធី "GDT Taxpayer App" ក្នុងគោលដៅធានាបាននូវប្រសិទ្ធភាព និងតម្លាភាពលើកិច្ចការគ្រប់គ្រងការប្រមូលចំណូលពន្ធដារ ក៏ដូចជាក្នុងន័យបង្កលក្ខណៈកាន់តែងាយស្រួល និងឆាប់រហ័សជូនម្ចាស់យានជំនិះ ក្នុងការបង់ប្រាក់ពន្ធតាមទូរស័ព្ទដៃ ដោយមិនចាំបាច់អញ្ជើញទៅបង់ប្រាក់ពន្ធនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ ឬតាមសាខាធនាគារពាណិជ្ជដែលជាដៃគូរបស់អគ្គនាយកដ្ឋានពន្ធដារ និងមិនចាំបាច់ទៅយកលតាបត្រនៅទីកន្លែងបង់ប្រាក់ពន្ធទៀតនោះឡើយ។ បន្ទាប់ពីម្ចាស់យានជំនិះបានបង់ប្រាក់ពន្ធតាមកម្មវិធីនេះរួចរាល់ អគ្គនាយកដ្ឋានពន្ធដារនឹងធ្វើការដឹកជញ្ជូនលតាបត្រនោះ ដល់ទីកន្លែងរបស់ម្ចាស់យានជំនិះតែម្តង។ អគ្គនាយកដ្ឋានពន្ធដារ សូមជម្រាប និងណែនាំពីអត្ថប្រយោជន៍ របៀបដំឡើង និងប្រើប្រាស់កម្មវិធីសម្រាប់បង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទតាមទូរស័ព្ទដៃដូចតទៅ៖

### I- អត្ថប្រយោជន៍នៃកម្មវិធីបង់ប្រាក់ពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទតាមទូរស័ព្ទដៃ

កម្មវិធីនេះនឹងបង្កលក្ខណៈងាយស្រួលដល់ម្ចាស់យានជំនិះជាអ្នកជាប់ពន្ធក្នុងការ៖

- ពិនិត្យមើលព័ត៌មានយានជំនិះដែលបានចុះបញ្ជី និងបានធ្វើបច្ចុប្បន្នភាពរួចរាល់ នៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យយានជំនិះរបស់អគ្គនាយកដ្ឋានពន្ធដារ
- បង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំរបស់ខ្លួន ដោយមិនចាំបាច់បំពេញព័ត៌មានក្នុងទម្រង់លិខិតប្រកាសពន្ធ
- ចំណេញពេលវេលា ដោយមិនចាំបាច់អញ្ជើញទៅបង់ប្រាក់ពន្ធនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ ឬ សាខាធនាគារពាណិជ្ជជាដៃគូរបស់អគ្គនាយកដ្ឋានពន្ធដារ
- ស្នើសុំ និងទទួលបានប័ណ្ណសម្គាល់ការបង់ពន្ធ ជាទម្រង់ឌីជីថល (E-Card) ភ្លាមៗ
- ទទួលបានលតាបត្រពន្ធមធ្យោបាយប្រចាំឆ្នាំ ដល់ទីកន្លែងរបស់ម្ចាស់យានជំនិះ
- ទទួលបាននូវសេចក្តីជូនដំណឹងផ្សេងៗដូចជា ៖ កាលបរិច្ឆេទនៃការប្រកាសបង់ពន្ធ កាលបរិច្ឆេទនៃការផុតកំណត់ការបង់ប្រាក់ពន្ធ ការប្រកាសបង់ប្រាក់ពន្ធខ្វះក្នុងការិយបរិច្ឆេទជាប់ពន្ធណាមួយ និងសេចក្តីជូនដំណឹងផ្សេងៗទៀត ពាក់ព័ន្ធនឹងប្រភេទពន្ធនេះ។



អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855) 23 886 700 Email: gdt@tax.gov.kh Website: www.tax.gov.kh

## II- របៀបដំឡើងកម្មវិធីនៅក្នុងទូរស័ព្ទដៃ

ដើម្បីអាចប្រើប្រាស់កម្មវិធីបង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ តាមទូរស័ព្ទដៃនេះ ម្ចាស់យានជំនិះអាចទាញយក និងដំឡើងកម្មវិធីនៅក្នុងទូរស័ព្ទដៃផ្ទាល់ខ្លួនដូចខាងក្រោម÷

- ***ចំពោះទូរស័ព្ទដៃដែលដំណើរការដោយប្រព័ន្ធប្រតិបត្តិការ Android÷*** សូមចូលទៅកាន់ "Play Store" រួចស្វែងរកពាក្យ "GDT Taxpayer App" បន្ទាប់មកទាញយក និងដំឡើងកម្មវិធីនេះនៅក្នុងទូរស័ព្ទដៃ
- ***ចំពោះទូរស័ព្ទដៃដែលដំណើរការដោយប្រព័ន្ធប្រតិបត្តិការ iOS÷*** សូមចូលទៅកាន់ "App Store" រួចស្វែងរកពាក្យ "GDT Taxpayer App" បន្ទាប់មកទាញយក និងដំឡើងកម្មវិធីនៅក្នុងទូរស័ព្ទដៃ។

## III- របៀបចូលប្រើប្រាស់ និងបង់ប្រាក់ពន្ធតាមរយៈកម្មវិធីបង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ តាមទូរស័ព្ទដៃ

បន្ទាប់ពីដំឡើងកម្មវិធីនេះនៅក្នុងទូរស័ព្ទដៃរួចហើយ ម្ចាស់យានជំនិះត្រូវ ÷

១. ចុះឈ្មោះ ដើម្បីបង្កើតគណនីប្រើប្រាស់ (សម្រាប់ម្ចាស់យានជំនិះដែលមិនទាន់មានគណនីប្រើប្រាស់) ដោយបំពេញនូវព័ត៌មានតម្រូវដូចខាងក្រោម÷

**១.១ សម្រាប់ម្ចាស់យានយន្ត÷** ឈ្មោះជាភាសាខ្មែរ ឈ្មោះជាភាសាឡាតាំង ភេទ ថ្ងៃខែឆ្នាំកំណើត សញ្ជាតិ លេខអត្តសញ្ញាណប័ណ្ណ ឬលេខលិខិតឆ្លងដែន សារអេឡិចត្រូនិក លេខទូរស័ព្ទ។

**១.២ សម្រាប់ភ្នាក់ងារសេវាកម្មពន្ធដារ÷** ឈ្មោះជាភាសាខ្មែរ ឈ្មោះជាភាសាឡាតាំង ភេទ ថ្ងៃខែឆ្នាំកំណើត សញ្ជាតិ លេខអត្តសញ្ញាណប័ណ្ណ ឬលេខលិខិតឆ្លងដែន សារអេឡិចត្រូនិក លេខទូរស័ព្ទ លេខសម្គាល់ភ្នាក់ងារសេវាកម្មពន្ធដារ ។

**១.៣ សម្រាប់អ្នកតំណាងសហគ្រាស÷** ឈ្មោះជាភាសាខ្មែរ ឈ្មោះជាភាសាឡាតាំង ភេទ ថ្ងៃខែឆ្នាំកំណើត សញ្ជាតិ លេខអត្តសញ្ញាណប័ណ្ណ ឬលេខលិខិតឆ្លងដែន សារអេឡិចត្រូនិក លេខទូរស័ព្ទ លេខអត្តសញ្ញាណកម្ម សារពើពន្ធរបស់សហគ្រាស ។

២. បន្ទាប់ពីបង្កើតគណនីរួច ម្ចាស់យានជំនិះអាចប្រើប្រាស់លេខអត្តសញ្ញាណប័ណ្ណ ឬលេខលិខិតឆ្លងដែន ឬសារអេឡិចត្រូនិក ឬលេខទូរស័ព្ទ ឬលេខអត្តសញ្ញាណកម្មពន្ធរូបវន្តបុគ្គល (TID) និងពាក្យសម្ងាត់ ដើម្បីចូលប្រើប្រាស់កម្មវិធី។

## IV- របៀបបញ្ចូលព័ត៌មានយានជំនិះដើម្បីបង់ប្រាក់ពន្ធ

១. ដើម្បីបង់ប្រាក់ពន្ធតាមកម្មវិធីនេះបាន លោក-លោកស្រីអាចបញ្ចូលព័ត៌មានយានជំនិះដែលត្រូវបង់ពន្ធតាម ០២ជម្រើស ដូចខាងក្រោម÷

**ជម្រើសទី ១÷**បញ្ចូលព័ត៌មានយានជំនិះដោយវាយបញ្ចូល ឬ ស្កេន **"លេខបារកូដលើប័ណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ"** (ឧទាហរណ៍÷ ***GDTVT000xxx000***) ឬ

**ជម្រើសទី ២÷** បញ្ចូលព័ត៌មានយានជំនិះដោយវាយបញ្ចូល ឬស្កេន **"លេខលតាបត្រពន្ធមធ្យោបាយដែលធ្លាប់បានបង់ប្រាក់ពន្ធនាឆ្នាំកន្លងមក"**

(ឧទាហរណ៍÷ លេខលតាបត្រពន្ធឆ្នាំ២០២០÷***202000000000x*** ឬ ឆ្នាំ២០១៩÷***201900000000x)*** ។

២. បន្ទាប់ពីបញ្ចូលព័ត៌មានយានជំនិះរួច ម្ចាស់យានជំនិះត្រូវពិនិត្យព័ត៌មានយានជំនិះរបស់ខ្លួន÷

២.១ ករណីព័ត៌មានយានជំនិះដែលបង្ហាញលើកម្មវិធី ត្រឹមត្រូវទៅនឹងព័ត៌មានយានជំនិះរបស់លោក-លោកស្រី សូមចុចប៊ូតុង*"**យល់ព្រម**"* រួចជ្រើសរើស ***លេខទូរស័ព្ទចុះឈ្មោះជាមួយកម្មវិធី*** ឬ ***លេខទូរស័ព្ទរបស់ម្ចាស់យានជំនិះ*** សម្រាប់ទទួលលេខកូដសម្ងាត់០៦ខ្ទង់ពីប្រព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីដាក់ឱ្យដំណើរការយានជំនិះទាំងនោះទៅក្នុងបញ្ជីបង់ប្រាក់ពន្ធ។

L202107070454 | TD3110

២.២ ករណីព័ត៌មានយានជំនិះដែលបង្ហាញលើកម្មវិធី មិនត្រឹមត្រូវទៅនឹងព័ត៌មានយានជំនិះរបស់លោក-លោកស្រី សូមចុចប៊ូតុង *"មិនយល់ព្រម"* រួចសូមទំនាក់ទំនងទៅកាន់លេខ ១២៧៧ ដើម្បីធ្វើបច្ចុប្បន្នភាពជាមួយអគ្គនាយកដ្ឋានពន្ធដារ។

V- **របៀបបង់ប្រាក់ពន្ធ**

១. ម្ចាស់យានជំនិះអាចបង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ម្តងមួយគ្រឿង ឬច្រើនគ្រឿង ដោយចុចបញ្ចូលព័ត៌មានយានជំនិះទាំងនោះចូលក្នុងកន្ត្រក **(Add to Cart)**។

**២.** ម្ចាស់យានជំនិះអាចស្នើសុំធ្វើប័ណ្ណសម្គាល់ការបង់ពន្ធ ដោយជ្រើសរើស ប៊ូតុង "**ស្នើសុំធ្វើប័ណ្ណសម្គាល់ការបង់ពន្ធ**"។

៣. បន្ទាប់មក ម្ចាស់យានជំនិះត្រូវជ្រើសរើសទីតាំងដែលទទួលលតាបត្រពន្ធ។

៤. បន្ទាប់មកលោក-លោកស្រីអាចធ្វើការបង់ប្រាក់ពន្ធតាមអនឡាញ (e-Payment) តាមរយៈធនាគារពាណិជ្ជដែលបានចុះអនុស្សរណៈជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**បញ្ជាក់**

- កម្មវិធីនេះអាចប្រើប្រាស់បានសម្រាប់តែយានជំនិះគ្រប់ប្រភេទទាំងឡាយណា ដែលបានចុះបញ្ជីរួចរាល់នៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ តែប៉ុណ្ណោះ
- ករណីយានជំនិះគ្រប់ប្រភេទដែលមិនទាន់បានចុះបញ្ជីក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ ម្ចាស់យានជំនិះត្រូវអញ្ជើញទៅបង់ប្រាក់ពន្ធនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ ឬតាមសាខាធនាគារពាណិជ្ជដែលចុះអនុស្សរណៈជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ម្ចាស់យានជំនិះត្រូវបង់កម្រៃសេវា ១០ ០០០ រៀល ក្នុងមួយគ្រឿង
- ក្នុង០១ប្រតិបត្តិការនៃការបង់ប្រាក់ពន្ធ ម្ចាស់យានជំនិះអាចបង់ប្រាក់ពន្ធបានអតិបរមា ១០គ្រឿងប៉ុណ្ណោះ
- ទីតាំងដែលអាចដឹកជញ្ជូនបាន គឺស្ថិតក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និងទីរួមខេត្តមួយចំនួនដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។ ករណីលោក-លោកស្រីជ្រើសរើសទីតាំងផ្សេងពីនេះ លោក-លោកស្រីត្រូវអញ្ជើញទៅទទួលលតាបត្រពន្ធ នៅសាខាពន្ធដារខេត្តដែលលោក-លោកស្រីស្ថិតនៅ ។

សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនងមកកាន់ GDT Call Center នៃអគ្គនាយកដ្ឋានពន្ធដារ តាមរយៈលេខ ១២៧៧ ចាប់ពីម៉ោង ៨:០០ នាទីព្រឹក ដល់ម៉ោង ៤:៤៥ នាទីរសៀល រៀងរាល់ថ្ងៃធ្វើការ។

អគ្គនាយកដ្ឋានពន្ធដារជឿជាក់យ៉ាងមុតមាំថា សាធារណជន ឬម្ចាស់យានជំនិះដែលជាអ្នកជាប់ពន្ធ នឹងទទួលបាននូវអត្ថប្រយោជន៍ជាច្រើនពីកម្មវិធីនេះ ជាពិសេសចំណេញពេលវេលា និងងាយស្រួលក្នុងការបង់ប្រាក់ពន្ធ ព្រមទាំងអាចតាមដានពីស្ថានភាពនៃការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទរបស់ខ្លួន បានទាន់ពេលវេលាទៀតផង។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការជាមួយរដ្ឋបាលសារពើពន្ធ ក្នុងការបំពេញកាតព្វកិច្ចបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ តាមរយៈទូរស័ព្ទដៃឱ្យបានផុសផុល និងប្រកបដោយប្រសិទ្ធភាពខ្ពស់ តាមការគួរ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋាន ពន្ធដារ

**គង់ វិបុល**

*សូមស្កែនទីនេះដើម្បីទាញយកកម្មវិធីមកប្រើប្រាស់*

GET IT ON Google Play    Download on the App Store

# រំហូរនៃការបង់ពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដោយប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ “GDT Taxpayer App”



# ផ្ទាំងរូបភាពកម្មវិធី






# ផ្ទាំងរូបភាពកម្មវិធី







